# ព្រះរាជក្រម

**លេខ នស/រកម/០១០៧/០០២**

## ច្បាប់ស្តីពី ច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃពិធីសារបន្ថែមនៃអនុសញ្ញា ស្តីពីការប្រឆាំងការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ



គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម

# ព្រះរាជក្រម

នស/រកម/០២០៧/០០២

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រ កត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃពិធីសារបន្ថែមនៃអនុសញ្ញា ស្តីពីការប្រឆាំងការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៦នាសម័យប្រជុំរដ្ឋសភា លើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់-ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី២ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ស/3

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការប្រឆាំងការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើឱ្យថោកទាបបុកម្នេញ ឬទណ្ឌកម្ម

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃពិធីសារបន្ថែមនៃអនុ-សញ្ញាស្តីពីការប្រឆាំងការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើឱ្យថោកទាបបុកម្នេញ ឬទណ្ឌកម្ម ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងសម័យប្រជុំលើកទី ៥៧ តាមសេចក្តីសម្រេចលេខ ៥៧/១៩៩ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០២ ហើយដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាចូលជាភាគីនៅទីក្រុងញូវយ៉ក នាថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៥ ដូចមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាអង្គការសហប្រជាជាតិនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម.០១០៧.០២៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

លេខ: ៥០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
[illegible] ជិនកេន

៥/៣

# ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការប្រឆាំងនឹងអំពើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម

**សេចក្តីសំរេចមហាសន្និបាតលេខ A/RES/57/199 អនុម័តនៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០២**

*បោះពុម្ពឡើងវិញ* 42 I.L.M. 26 (2003)

## ជំពូកទី ១
## គោលការណ៍ទូទៅ

**មាត្រា ១.-**

ពិធីសារបន្ថែមនេះមានគោលបំណងបង្កើតនូវប្រព័ន្ធទស្សនកិច្ចជាប្រចាំ ដែលអនុវត្តដោយស្ថាប័នជាតិ ឬស្ថាប័នអន្តរជាតិឯករាជ្យ ទៅគ្រប់ទីកន្លែងដែលឃុំឃាំងជនដែលត្រូវបានដកហូតសេរីភាព ដើម្បីការពារប្រឆាំងនឹងអំពើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ ឬអំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ។

**មាត្រា ២.-**

១. អនុគណៈកម្មាធិការទប់ស្កាត់អំពើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្មនៃគណៈកម្មាធិការប្រឆាំងនឹងអំពើទារុណកម្ម (ហៅកាត់ថា " អនុគណៈកម្មាធិការទប់ស្កាត់ " ) នឹងត្រូវ បានបង្កើត ហើយត្រូវអនុវត្តមុខងារទាំងឡាយដូចមានចែងក្នុងពិធីសារនេះ។

២. អនុគណៈកម្មាធិការទប់ស្កាត់ ត្រូវអនុវត្តមុខងាររបស់ខ្លួនក្នុងក្របខណ្ឌនៃធម្មនុញ្ញអង្គការសហប្រជាជាតិ និងត្រូវអនុវត្តស្របតាមគោលបំណង និងគោលការណ៍នៃធម្មនុញ្ញនេះព្រមទាំងបទដ្ឋាន នានានៃអង្គការសហប្រជាជាតិ ដែលចែងពីប្រព្រឹត្តិកម្មលើជនដែលត្រូវបានដកហូតសេរីភាព ។

៣. អនុគណៈកម្មាធិការទប់ស្កាត់ ត្រូវអនុវត្តស្របតាមគោលការណ៍រក្សាការសម្ងាត់ អព្យាក្រិត្យ គ្មានប្រកាន់ និន្នាការ សាកលនិយម និងគោលការណ៍សត្យានុមតិ ។

៤. អនុគណៈកម្មាធិការទប់ស្កាត់ និងរដ្ឋភាគី ត្រូវសហការគ្នាក្នុងការអនុវត្តពិធីសារនេះ ។

**មាត្រា ៣.-**

រដ្ឋភាគីនិមួយៗត្រូវបង្កើត ចាត់តាំង ឬដំណើរការនូវស្ថាប័នធ្វើទស្សនកិច្ចកំរិតជាតិ មួយ ឬច្រើន ដើម្បីប្រឆាំងនឹងអំពើទារុណកម្ម អំពើឃោរឃៅអំពើអមនុស្សធម៌អំពើធ្វើទុក្ខបុកម្នេញឬទណ្ឌកម្ម (ហៅកាត់ថា "យន្តការ ទប់ស្កាត់ថ្នាក់ជាតិ ") ។

**មាត្រា ៤.-**

១. អនុលោមតាមពិធីសារនេះ រដ្ឋភាគីនិមួយៗត្រូវអនុញ្ញាតអោយធ្វើទស្សនកិច្ចនៅគ្រប់ទីកន្លែងដែលស្ថិតក្រោមយុត្តាធិការនិងការគ្រប់គ្រងរបស់ខ្លួន តាមរយៈយន្តការដែលមានចែងក្នុងមាត្រា ២ និង

មាត្រា៣ ដែលជាកន្លែងឃុំឃាំងជនដែលត្រូវបានដកហូតសេរីភាព តាមអំណាចបទបញ្ជាដែលចេញដោយអាជ្ញាធរសាធារណៈ ឬតាមគំនិតផ្តួចផ្តើម ឬការឯកភាព ឬការអនុញ្ញាតរបស់ខ្លួន (ហៅកាត់ថា "មន្ទីរឃុំឃាំង")។ ទស្សនកិច្ចនេះត្រូវបានធ្វើឡើង ក្នុងស្មារតីពង្រឹងការការពារជនទាំងឡាយទល់នឹងអំពើទារុណកម្ម អំពើ ឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្មប្រសិនបើមានការចាំបាច់។

២. សំរាប់គោលបំណងពិធីសារនេះ ពាក្យថា " ការដកហូតសេរីភាព " សំដៅដល់គ្រប់រូប ភាពនៃការឃុំឃាំង ដាក់ពន្ធនាគារ ឬការដាក់មនុស្សនៅកន្លែងឃុំខ្លួនសាធារណៈ ឬឯកជន ដែលអំពើនេះមិនអនុញ្ញាតអោយ ជននោះចាកចេញតាមចិត្ត ហើយការឃុំឃាំងនេះធ្វើឡើងតាមបញ្ជាតុលាការ អំណាច រដ្ឋបាល ឬតាមអំណាចផ្សេងទៀត។

## ជំពូកទី ២
## អនុគណៈកម្មាធិការទប់ស្កាត់

**មាត្រា ៥.-**

១. អនុគណៈកម្មាធិការទប់ស្កាត់ ត្រូវមានសមាជិក ១០រូប។ បន្ទាប់ពីសច្ចាប័ន ឬការចូលជាសមាជិកទី ៥០ នៃ ពិធីសារបន្ថែមនេះ ចំនួនសមាជិកនៃអនុគណៈកម្មាធិការទប់ស្កាត់ ត្រូវកើនដល់ ២៥រូប។

២. សមាជិកនៃអនុគណៈកម្មាធិការទប់ស្កាត់ នឹង ត្រូវបានជ្រើសតាំងចេញពីបុគ្គលដែលមានសីលធម៌ ចំណេះដឹងខ្ពស់ មានបទពិសោធន៍វិជ្ជាជីវៈច្បាស់លាស់ ក្នុងវិស័យគ្រប់គ្រងយុត្តិធម៌ ជាពិសេសបទពិសោធន៍គ្រប់គ្រង ពន្ធនាគារព្រហ្មទណ្ឌ ឬការគ្រប់គ្រងនគរបាល ឬក្នុងវិស័យផ្សេងៗដែលទាក់ទិននិងគ្រប់គ្រងជនដែល ត្រូវបានដកហូតសេរីភាព។

៣. ការកំណត់សមាសភាពនៃអនុគណៈកម្មាធិការទប់ស្កាត់ ត្រូវផ្អែកលើសមភាពនៃតំបន់ភូមិសាស្ត្រ និងតំណាង ប្រជាពលរដ្ឋច្រើន និងប្រព័ន្ធច្បាប់នៃរដ្ឋភាគីទានា។

៤. ការកំណត់សមាសភាពនៃអនុគណៈកម្មាធិការទប់ស្កាត់ត្រូវពិចារណាលើសមភាពយ៉េនឌ័រ ដោយផ្អែកលើគោលការណ៍សមភាពនិងការគ្មានការរើសអើង ។

៥. ក្នុងសមាសភាពនៃអនុគណៈកម្មាធិការទប់ស្កាត់ មិនអាចមានសមាជិក ២រូប ដែលមានសញ្ជាតិមកពីរដ្ឋតែមួយបានទេ។

៦. សមាជិកនៃអនុគណៈកម្មាធិការទប់ស្កាត់ ត្រូវបំពេញមុខងារតាមសមត្ថភាពផ្ទាល់ខ្លួន ត្រូវមានឯករាជ្យភាព និងអព្យាក្រិតភាព ហើយត្រូវមានវត្តមានដើម្បីបំរើការងាររបស់អនុគណៈកម្មាធិការទប់ស្កាត់ អោយមានប្រសិទ្ធភាព ។

**មាត្រា ៦.-**

១. អនុលោមតាមកថាខណ្ឌទី២ រដ្ឋភាគីនិមួយៗអាចតែងតាំងបេក្ខជនបានត្រឹម ២រូប ដែលមានសមត្ថភាព និងបំពេញតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ៥ ហើយរដ្ឋភាគីត្រូវផ្តល់ពត៌មាន ពិស្តារ ពីសមត្ថភាពរបស់បុគ្គល ដែលខ្លួនតែងតាំង ។

២. បេក្ខជនដែលទទួលការតែងតាំង ត្រូវមានសញ្ជាតិរបស់រដ្ឋភាគីនៃពិធីសារនេះ។

ក- យ៉ាងហោចណាស់មានបេក្ខជន ១រូប មានសញ្ជាតិរបស់រដ្ឋភាគីដែលតែងតាំង

ខ- រដ្ឋភាគីមិនអាចតែងតាំងបេក្ខជនលើសពី ២រូប បានឡើយ

គ- មុននឹងតែងតាំងបេក្ខជនដែលមានសញ្ជាតិរបស់រដ្ឋភាគីផ្សេង រដ្ឋត្រូវសុំ នឹងមានការយល់ព្រមពីរដ្ឋភាគីនោះ។

៣. យ៉ាងហោចណាស់ប្រាំ (៥)ខែ មុនកាលបរិច្ឆេទកិច្ចប្រជុំរបស់រដ្ឋភាគី បើការបោះឆ្នោតនឹងត្រូវធ្វើឡើង ក្នុងរយៈពេលនេះ អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ត្រូវសរសេរលិខិតជូនទៅរដ្ឋភាគីដើម្បីកោះ អញ្ជើញអោយរដ្ឋទាំងនោះដាក់ជូនការតែងតាំងរបស់គេក្នុងរយៈពេលបី (៣)ខែ។ អគ្គលេខាធិការ ត្រូវ ដាក់ជូនបញ្ជីរាយនាមអ្នកដែលទទួលការតែងតាំងតាមអក្ខរក្រម ដោយបញ្ជាក់ពីរដ្ឋភាគីដែលតែងតាំង ផង។

**មាត្រា ៧.-**

១. សមាជិកនៃអនុគណៈកម្មាធិការទប់ស្កាត់ នឹងត្រូវជ្រើសតាំងតាមវិធីដូចខាងក្រោម :

ក- តាមការពិចារណាលើការបំពេញតាមលក្ខខណ្ឌនិងលក្ខណៈវិនិច្ឆ័យក្នុងមាត្រា ៥ នៃពិធីសារនេះ ។

ខ- ការបោះឆ្នោតជ្រើសតាំងដំបូងត្រូវធ្វើឡើងមិនអោយលើសពី ៦ខែ បន្ទាប់ពីការចូលជាធរមាន នៃ ពិធីសារនេះឡើយ។

គ- រដ្ឋភាគីត្រូវជ្រើសតាំងសមាជិកអនុគណៈកម្មាធិការតាមការបោះឆ្នោតជាសម្ងាត់។

ឃ- ការបោះឆ្នោតជ្រើសតាំងសមាជិកអនុគណៈកម្មាធិការត្រូវធ្វើឡើងក្នុងកិច្ចប្រជុំរដ្ឋភាគីរៀងរាល់ ពីរ ឆ្នាំម្តង ដែលកោះប្រជុំដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ។ ចំនួន ២/៣ នៃរដ្ឋភាគី បង្កើតបានជាកូរ៉ុមនៃកិច្ចប្រជុំនេះ អ្នកជាប់ឆ្នោតជាសមាជិកអនុគណៈកម្មាធិការទប់ស្កាត់ ត្រូវទទួលបានចំនួនសន្លឹកឆ្នោតច្រើនបំផុតនិងទទួលបានសម្លេងភាគច្រើនដាច់ខាតពីតំណាងរដ្ឋភាគី ដែលវត្តមាននិងបោះឆ្នោត ។

២. ក្នុងដំណើរការបោះឆ្នោត ប្រសិនបើមានបេក្ខជនពីរនាក់របស់រដ្ឋភាគីមួយមានសិទ្ធិធ្វើជាសមាជិកនៃអនុគណៈកម្មាធិការទប់ស្កាត់បេក្ខជនដែលទទួលបានសម្លេងឆ្នោតច្រើនជាង ត្រូវបានតំណែងជាសមាជិកនៃអនុគណៈកម្មាធិការទប់ស្កាត់។ ក្នុងករណីដែលបេក្ខជនទាំងពីរទទួលបានសម្លេងស្មើគ្នា

ត្រូវអនុវត្តតាមនីតិវិធី ដូចខាងក្រោម :

ក- កាលណាមានបេក្ខជនតែម្នាក់ ដែលទទួលការតែងតាំងពីរដ្ឋភាគី ដែលជារដ្ឋដែលខ្លួនមានសញ្ជាតិ បេក្ខជននោះត្រូវបានតំណែងជាសមាជិកនៃអនុគណៈកម្មាធិការទប់ស្កាត់ ។

ខ- កាលណាមានបេក្ខជនទាំងពីរបានទទួលការតែងតាំងពីរដ្ឋភាគី ដែលជារដ្ឋដែលខ្លួនមានសញ្ជាតិ ត្រូវរៀបចំការបោះឆ្នោតដាច់ដោយឡែក ដើម្បីកំណត់យកបេក្ខជនណាមួយដែលជាសមាជិកនៃអនុគណៈកម្មាធិការទប់ស្កាត់ ។

គ- ក្នុងករណីដែលគ្មានបេក្ខជនណាមួយត្រូវតែងតាំងដោយរដ្ឋភាគី ដែលជារដ្ឋដែលខ្លួនមានសញ្ជាតិទេ ត្រូវរៀបចំការបោះឆ្នោតដាច់ដោយឡែក ដើម្បីកំណត់យកបេក្ខជនណាមួយដែលជាសមាជិកនៃអនុគណៈកម្មាធិការទប់ស្កាត់ ។

**មាត្រា ៨.-**

ក្នុងករណីដែលសមាជិកណាម្នាក់នៃអនុគណៈកម្មាធិការទប់ស្កាត់ទទួលមរណភាពលាលែងពីតំណែងឬមិនអាចបំពេញភារកិច្ចបាន ដោយមូលហេតុណាមួយរដ្ឋភាគីដែលបានតែងតាំងសមាជិកនោះត្រូវតែងតាំងបុគ្គល ម្នាក់ដែលមានសិទ្ធិសមស្របមានលក្ខណៈសម្បត្តិនិងបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៥ ដោយពិចារណាលើភាពចាំបាច់នៃសមភាពក្នុងចំណោមមុខជំនាញផ្សេងៗអោយបំរើការងាររហូតដល់កិច្ចប្រជុំបន្ទាប់ នៃរដ្ឋភាគីហើយត្រូវមានការឯកភាពពីរដ្ឋភាគីភាគច្រើនផង ។ ត្រូវចាត់ទុកថាមានការឯកភាព លើកលែងតែមានរដ្ឋ ភាគីពាក់កណ្តាលឬលើសពីនេះឆ្លើយបដិសេធក្នុងរយៈពេល ០៦សប្តាហ៍ក្រោយពីអគ្គលេខាធិការអង្គការសហប្រជាជាតិបានផ្តល់ពត៌មានពីការតែងតាំងនោះ ។

**មាត្រា ៩.-**

សមាជិកនៃអនុគណៈកម្មាធិការទប់ស្កាត់ត្រូវបានបោះឆ្នោតជ្រើសតាំងសំរាប់អាណត្តិ ០៤ឆ្នាំ ។បន្ទាប់ពីទទួលបានការតែងតាំងសមាជិកនេះអាចមានសិទ្ធិឈរឈ្មោះតែម្តងទៀតប៉ុណ្ណោះ ។ អាណត្តិនៃសមាជិកពាក់កណ្តាលដែលបានជាប់ឆ្នោតលើកទី១ ត្រូវចប់នៅចុងឆ្នាំទី២ហើយបន្ទាប់ពីការបោះឆ្នោតលើកទី១ប្រធានអង្គប្រជុំត្រូវជ្រើសរើសឈ្មោះសមាជិកទាំងនេះតាមរយៈការចាប់ឆ្នោត ដូចចែងក្នុងវាក្យខណ្ឌ ១-ឃ នៃមាត្រា ៧ ។

**មាត្រា ១០.-**

១. អនុគណៈកម្មាធិការទប់ស្កាត់ត្រូវបោះឆ្នោតជ្រើសតាំងមន្ត្រីការងារសំរាប់អាណត្តិ២ឆ្នាំ ។ មន្ត្រីការងារនេះ អាចឈរឈ្មោះសាជាថ្មីបាន ។

២. អនុគណៈកម្មាធិការទប់ស្កាត់ត្រូវបង្កើតវិធាននីតិវិធីសំរាប់ការងាររបស់ខ្លួន ។ វិធានទាំងនោះត្រូវចែងថា :

ក- សមាជិកពាក់កណ្តាល បូក មួយ បង្កើតបានជាកូរ៉ុម

ខ- សេចក្តីសំរេចរបស់អនុគណៈកម្មាធិការទប់ស្កាត់ ត្រូវធ្វើឡើងដោយសម្លេងភាគច្រើននៃសមាជិកដែលវត្តមាន

គ- អនុគណៈកម្មាធិការទប់ស្កាត់ ត្រូវប្រជុំក្នុងបន្ទប់សម្ងាត់ ។

៣. អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ត្រូវកោះប្រជុំកិច្ចប្រជុំអនុគណៈកម្មាធិការទប់ស្កាត់លើកដំបូង ។ បន្ទាប់ពីប្រជុំកិច្ចប្រជុំលើកដំបូង អនុគណៈកម្មាធិការទប់ស្កាត់ត្រូវជួបប្រជុំតាមពេលវេលាដូចមានកំណត់ក្នុងវិធាននិងកម្មវិធីការងារ ។ អនុគណៈកម្មាធិការទប់ស្កាត់ និងគណៈកម្មាធិការប្រឆាំងអំពើទារុណកម្ម ត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួនក្នុងពេលជាមួយគ្នា យ៉ាងហោចណាស់មួយឆ្នាំម្តង។

## ជំពូកទី ៣

## អាណត្តិការងារនៃអនុគណៈកម្មាធិការទប់ស្កាត់

**មាត្រា ១១.-**

អនុគណៈកម្មាធិការទប់ស្កាត់ត្រូវ:

១. ធ្វើទស្សនកិច្ចតាមកន្លែងទាំងឡាយដូចមានចែងក្នុងមាត្រា ៤ និងធ្វើអនុសាសន៍ជូនរដ្ឋភាគីពាក់ព័ន្ធនិងការការពារជនដែលត្រូវបានដកហូតសេរីភាព អោយរួចផុតពីអំពើទារុណកម្ម អំពើឃោរឃៅ អំពើ អមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម។

២. ចំពោះកិច្ចការដែលពាក់ព័ន្ធនិងយន្តការទប់ស្កាត់ថ្នាក់ជាតិ អនុគណៈកម្មាធិការត្រូវ:

ក- ផ្តល់យោបល់និងជួយរដ្ឋភាគីក្នុងការបង្កើតយន្តការទាំងនោះ កាលណាមានការចាំបាច់។

ខ- ប្រសិនបើមានការចាំបាច់ រក្សាទំនាក់ទំនងជាសម្ងាត់ជាមួយយន្តការទប់ស្កាត់ថ្នាក់ជាតិ និងផ្តល់ការបណ្តុះបណ្តាលនិងជំនួយបច្ចេកទេសដល់យន្តការទាំងនោះ ក្នុងគោលបំណងពង្រឹងសមត្ថភាពយន្តការ ទាំងនោះ។

គ- ផ្តល់យោបល់និងជួយយន្តការទាំងនោះធ្វើការវាយតម្លៃសេចក្តីត្រូវការ និងមធ្យោបាយដែលចាំបាច់សំរាប់ពង្រឹងការការពារជនដែលត្រូវបានដកហូតសេរីភាព អោយរួចផុតពីអំពើទារុណកម្ម អំពើ ឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម។

ឃ-ធ្វើអនុសាសន៍ និងសេចក្តីសង្កេតចំពោះរដ្ឋភាគី ក្នុងគោលបំណងពង្រឹងសមត្ថភាព និងអាណត្តិការងាររបស់យន្តការទប់ស្កាត់ថ្នាក់ជាតិ ដើម្បីទប់ស្កាត់អំពើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម។

៣-សហការជាមួយស្ថាប័ននិងយន្តការទាំងឡាយរបស់អង្គការសហប្រជាជាតិ ព្រមទាំងស្ថាប័ន ឬអង្គការអន្តរជាតិ អង្គការប្រចាំតំបន់ អង្គការជាតិ និងអង្គការដែលធ្វើសកម្មភាពពង្រឹងការការពារមនុស្សពី

អំពើ ទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ។

**មាត្រា ១២.-**

ដើម្បីអោយអនុគណៈកម្មាធិការទប់ស្កាត់មានលទ្ធភាពអនុវត្តអាណត្តិការងារដូចមានចែងក្នុងមាត្រា ១១ នៃ ពិធីសារបន្ថែមនេះ រដ្ឋភាគីត្រូវៈ

១. ទទួលអនុគណៈកម្មាធិការទប់ស្កាត់នៅក្នុងដែនដីរបស់ខ្លួន ហើយត្រូវផ្តល់លទ្ធភាពអោយអនុគណៈកម្មាធិការនេះ ចូលទៅក្នុងកន្លែងឃុំឃាំងដូចមានចែងក្នុងមាត្រា ៤ នៃពិធីសារបន្ថែមនេះ ។

២. ត្រូវផ្តល់ពត៌មានចាំបាច់ទាំងអស់ជូនអនុគណៈកម្មាធិការទប់ស្កាត់តាមសំណើ សំរាប់ការវាយតម្លៃលើសេចក្តីត្រូវការនិងវិធានការដែលត្រូវអនុម័ត ដើម្បីពង្រឹងការការពារជនដែលត្រូវបានដកហូតសេរីភាពអោយរួច ផុតពីអំពើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ។

៣. ជំរុញនិងសំរួលទំនាក់ទំនងរវាង អនុគណៈកម្មាធិការទប់ស្កាត់ និង យន្តការទប់ស្កាត់ថ្នាក់ជាតិ ។

**មាត្រា ១៣.-**

១. អនុគណៈកម្មាធិការទប់ស្កាត់ ត្រូវបង្កើតកម្មវិធីធ្វើទស្សនកិច្ចជាប្រចាំទៅកាន់រដ្ឋភាគី ដើម្បីបំពេញភារកិច្ច របស់ខ្លួន ជាជំហ៊ានដំបូង ដូចមានចែងនៅក្នុងមាត្រា ១១ ។

២. បន្ទាប់ពីការពិគ្រោះយោបល់អនុគណៈកម្មាធិការទប់ស្កាត់ ត្រូវជូនដំណឹងពីកម្មវិធីរបស់ខ្លួនទៅរដ្ឋភាគី ដើម្បីអោយរដ្ឋទាំងនោះ ធ្វើការរៀបចំជាក់ស្តែងភ្លាមៗដើម្បីសំរួលដំណើរទស្សនកិច្ច ។

៣. ដំណើរទស្សនកិច្ចត្រូវធ្វើឡើងដោយសមាជិកអនុគណៈកម្មាធិការទប់ស្កាត់ យ៉ាងហោចណាស់២រូប ។ ប្រសិនបើមានការចាំបាច់ សមាជិកទាំងនេះអាចអមដំណើរដោយអ្នកជំនាញដែលមានបទពិសោធន៍ និងចំណេះដឹងក្នុងអាជីពនៃវិស័យដែលស្ថិតក្នុងវិសាលភាពរបស់ពិធីសារបន្ថែមនេះ ហើយអ្នកអមដំណើរ ត្រូវបានជ្រើសរើសចេញពីក្រុមអ្នកជំនាញដែលបានរៀបចំតាមមូលដ្ឋានសំណើ ដែលបានធ្វើឡើងដោយ រដ្ឋភាគី ឧត្តមស្នងការសិទ្ធិមនុស្សនិងមជ្ឈមណ្ឌលទប់ស្កាត់បទឧក្រិដ្ឋ នៃអង្គការសហប្រជាជាតិ ។ ដើម្បីរៀបចំបញ្ជីក្រុមអ្នកជំនាញនេះ រដ្ឋភាគីសាមីត្រូវស្នើឈ្មោះអ្នកជំនាញជាតិមិនអោយលើសពី ៥រូបឡើយ ។ រដ្ឋភាគីសាមីអាចលើកសំណើសុំបន្ថែមអ្នកឯកទេសពិសេសក្នុងក្រុមទស្សនកិច្ច ដែលក្នុងករណីនេះ អនុគណៈកម្មាធិការទប់ស្កាត់ត្រូវស្នើសុំថែមអ្នកជំនាញ ០១ រូបទៀតដែរ ។

៤. ប្រសិនបើអនុគណៈកម្មាធិការទប់ស្កាត់យល់ថាសមស្របអនុគណៈកម្មាធិការនេះអាចស្នើធ្វើទស្សន-កិច្ចតាមដានខ្លីមួយបន្ថែមលើទស្សនកិច្ចជាប្រចាំ ។

**មាត្រា ១៤.-**

១. ដើម្បីផ្តល់លទ្ធភាពអោយអនុគណៈកម្មាធិការទប់ស្កាត់ អាចបំពេញអាណត្តិការងាររបស់ខ្លួនបាន

រដ្ឋ ភាគីនៃ ពិធីសារបន្ថែមនេះត្រូវចាត់វិធានការផ្តល់អនុគណៈកម្មាធិការនូវៈ

ក- សិទ្ធិទទួលពត៌មានដោយគ្មានការរឹតត្បិត អំពីចំនួនមនុស្សដែលត្រូវបានដកហូតសេរីភាពនៅក្នុងមន្ទីរឃុំឃាំង ដូចមានចែងក្នុងមាត្រា ៤ ព្រមទាំងចំនួនទីកន្លែង និងទីតាំងនៃកន្លែងទាំងនោះផង ។

ខ- សិទ្ធិទទួលពត៌មានដោយគ្មានការរឹតត្បិត ដែលនិយាយពីប្រព្រឹត្តិកម្មលើជនទាំងនេះព្រមទាំងស្ថាន ភាពនៃការឃុំឃាំងផងដែរ ។

គ- សិទ្ធិចេញចូលដោយគ្មានការរឹតទៅគ្រប់កន្លែងឃុំឃាំង ទីតាំង និងរចនាសម្ព័ន្ធនៃមន្ទីរឃុំឃាំងដោយអនុលោមកថាខណ្ឌទី ២ ។

ឃ-ឱកាសធ្វើសំភាសន៍ជាឯកជនជាមួយជនដែលត្រូវបានដកហូតសេរីភាព ដោយគ្មានសាក្សី តាម ការ សំភាសន៍ផ្ទាល់ ឬតាមរយៈអ្នកបកប្រែភាសា បើយល់ថាសមស្រប និងសំភាសន៍ជាមួយបុគ្គលដទៃទៀត ដែលអនុគណៈកម្មាធិការទប់ស្កាត់យល់ថាអាចផ្តល់ពត៌មានដែលពាក់ព័ន្ធ ។

ង- សេរីភាពជ្រើសរើសទីកន្លែងដែលខ្លួនចង់ធ្វើទស្សនកិច្ច និងបុគ្គលដែលខ្លួនចង់សំភាសន៍ ។ លក្ខខណ្ឌចំនួនទីកន្លែង និងទីតាំងនៃកន្លែងទាំងនោះផង ។

២. ការជំទាស់ទៅនឹងការទស្សនកិច្ចក្នុងមន្ទីរឃុំឃាំងណាមួយ អាចធ្វើឡើងតែក្នុងករណីមានភាពអាសន្ន និងមូលហេតុចាំបាច់ខាងការការពារជាតិ សុវត្ថិភាពសាធារណៈ គ្រោះមហន្តរាយធម្មជាតិ ឬចលាចលធ្ងន់ធ្ងរ កើតឡើងនៅកន្លែងដែលត្រូវធ្វើទស្សនកិច្ច ។

**មាត្រា ១៥.-**

គ្មានអាជ្ញាធរ ឬមន្ត្រីណាអាចបញ្ជា អនុវត្ត អនុញ្ញាត ឬមិនអើពើចំពោះការដាក់ទណ្ឌកម្មប្រឆាំងនឹងបុគ្គល ឬអង្គការណាមួយពីមូលហេតុដែលបុគ្គលនេះបានផ្តល់ពត៌មានជូនអនុគណៈកម្មាធិការទប់ស្កាត់ ឬប្រតិភូនៃអនុគណៈកម្មាធិការនេះបានទេ ទោះបីជាពត៌មាននោះពិត ឬមិនពិតក្តី ហើយបុគ្គល ឬអង្គការនេះមិនត្រូវទទួលរងការចោទប្រកាន់តាមវិធីណាមួយបានឡើយ ។

**មាត្រា ១៦.-**

១. អនុគណៈកម្មាធិការទប់ស្កាត់ត្រូវផ្តល់អនុសាសន៍ និងការសង្កេតរបស់ខ្លួនដោយសម្ងាត់ទៅកាន់រដ្ឋភាគី និងជូនយន្តការថ្នាក់ជាតិ បើមានការពាក់ព័ន្ធ ។

២. អនុគណៈកម្មាធិការទប់ស្កាត់ ត្រូវបោះពុម្ពផ្សាយរបាយការណ៍របស់ខ្លួន រួមជាមួយយោបល់របស់រដ្ឋភាគីដែលពាក់ព័ន្ធនៅពេលដែលរដ្ឋភាគីបានស្នើសុំផ្តល់យោបល់ ។ ប្រសិនបើរដ្ឋភាគីផ្សាយតែផ្នែកមួយនៃរបាយការណ៍ជាសាធារណៈ អនុគណៈកម្មាធិការអាចផ្សាយរបាយការណ៍នោះទាំងស្រុង ឬមួយ

ផ្នែកក៏បាន ។ ប៉ុន្តែមិនអាចចុះផ្សាយពត៌មានផ្ទាល់ខ្លួនដោយគ្មានការយល់ព្រមជាក់លាក់ពីសាមីជនបានឡើយ ។

៣. អនុគណៈកម្មាធិការទប់ស្កាត់ ត្រូវធ្វើការបកស្រាយពន្យល់ពីរបាយការណ៍ផ្លូវការអំពីសកម្មភាពប្រចាំឆ្នាំ ជូនគណៈកម្មាធិការប្រឆាំងអំពើទារុណកម្ម ។

៤. ប្រសិនបើរដ្ឋភាគីមិនព្រមសហការជាមួយអនុគណៈកម្មាធិការទប់ស្កាត់ តាមមាត្រា ១២ និងមាត្រា ១៤ ឬមិនព្រមចាត់វិធានការដើម្បីកែលំអស្ថានភាពតាមស្មារតីនៃអនុសាសន៍របស់អនុគណៈកម្មាធិការទប់ស្កាត់ទេ តាមសំណើរបស់អនុគណៈកម្មាធិការទប់ស្កាត់និងបន្ទាប់ពីរដ្ឋភាគីបានទទួលឱកាសបញ្ជាក់ពីទស្សនៈរបស់ខ្លួនគណៈកម្មាធិការប្រឆាំងអំពើទារុណកម្មអាចសំរេចតាមសម្លេងភាគច្រើនពីសមាជិករបស់ខ្លួនដើម្បីធ្វើសេចក្តីប្រកាសសាធារណៈអំពីបញ្ហា ឬបោះពុម្ពផ្សាយរបាយការណ៍របស់អនុគណៈកម្មាធិការទប់ស្កាត់ ។

## ជំពូកទី ៤
## យន្តការទប់ស្កាត់ថ្នាក់ជាតិ

**មាត្រា ១៧.-**

រដ្ឋភាគីនិមួយៗ ត្រូវរក្សាទុក ចាត់តាំង ឬបង្កើតយន្តការទប់ស្កាត់ថ្នាក់ជាតិមួយ ឬច្រើន ដើម្បីទប់ស្កាត់អំពើទារុណកម្មថ្នាក់ជាតិ យ៉ាងហោចណាស់មួយឆ្នាំបន្ទាប់ពីការចូលជាធរមាន ការធ្វើសច្ចាប័ន ឬការចូលជាសមាជិកនៃពិធីសារបន្ថែមនេះ ។ យន្តការទាំងឡាយដែលបង្កើតឡើងដោយអង្គភាពវិមជ្ឈការ អាចត្រូវបានកំណត់ថា ជាអង្គភាពទប់ស្កាត់ថ្នាក់ជាតិសំរាប់គោលបំណងនៃអនុសញ្ញានេះបាន ប្រសិនបើយន្តការទាំងនោះស្របទៅតាម បទប្បញ្ញត្តិនៃពិធីសារបន្ថែមនេះ ។

**មាត្រា ១៨.-**

១. រដ្ឋភាគីនិមួយៗត្រូវធានានូវឯករាជ្យភាពមុខងារនៃយន្តការទប់ស្កាត់ថ្នាក់ជាតិ ព្រមទាំងឯករាជ្យភាពនៃបុគ្គលិករបស់ស្ថាប័ននេះផង ។

២. រដ្ឋភាគីត្រូវចាត់វិធានការចាំបាច់ ដើម្បីអោយអ្នកជំនាញនៃយន្តការជាតិ មានសមត្ថភាពនិងចំណេះដឹង ដែលចាំបាច់ ។ រដ្ឋភាគីត្រូវព្យាយាមដើម្បីសំរេចបាននូវសមភាពយ៉េនឌ័រ និងមានតំណាងគ្រប់គ្រាន់ពីក្រុមជនជាតិដើមភាគតិច និងក្រុមជាតិពន្ធនៅក្នុងប្រទេស ។

៣. រដ្ឋភាគី ត្រូវចាត់វិធានការ ដើម្បីអោយមានធនធានចាំបាច់សំរាប់ដំណើរការយន្តការទប់ស្កាត់ថ្នាក់ជាតិ ។

៤. ក្នុងពេលបង្កើតយន្តការទប់ស្កាត់ថ្នាក់ជាតិ រដ្ឋភាគីត្រូវតែពិចារណាអោយបានល្អិតល្អន់នូវគោលការណ៍ដែលពាក់ព័ន្ធនឹងស្ថានភាព និងការប្រព្រឹត្តិទៅនៃស្ថាប័នជាតិដើម្បីការពារនិងលើកស្ទួយសិទ្ធិមនុស្ស ។

**មាត្រា ១៩.-**

យ៉ាងហោចណាស់ យន្តការទប់ស្កាត់ថ្នាក់ជាតិ ត្រូវមានអំណាចដូចខាងក្រោម :

១. ពិនិត្យជាប្រចាំនូវប្រព្រឹត្តិកម្មលើជនដែលត្រូវបានដកសេរីភាព នៅតាមកន្លែងដូចបានបញ្ជាក់ក្នុងមាត្រា ៤ ក្នុងស្មារតីពង្រឹង ការការពារជនទាំងនោះពីអំពើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ។

២. ផ្តល់អនុសាសន៍ជូនអាជ្ញាធរពាក់ព័ន្ធដោយមានគោលបំណងកែលំអប្រព្រឹត្តិកម្ម និងស្ថានភាពរបស់ជនដែលត្រូវបានដកសេរីភាព និងដើម្បីទប់ស្កាត់អំពើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើ ទុក្ខបុកម្នេញ ឬទណ្ឌកម្ម ស្របតាមស្មារតីនៃស្តង់ដាររបស់អង្គការសហប្រជាជាតិ ដែលពាក់ព័ន្ធ ។

៣. ដាក់ជូនសំណើ និងសេចក្តីសង្កេតលើច្បាប់ដែលមានស្រាប់ ឬសេចក្តីព្រាងច្បាប់ ។

**មាត្រា ២០.-**

ដើម្បីផ្តល់លទ្ធភាពអោយអនុគណៈកម្មាធិការទប់ស្កាត់ អាចបំពេញអាណត្តិការងាររបស់ខ្លួនបាន រដ្ឋភាគីនៃពិធីសារបន្ថែមនេះត្រូវចាត់វិធានការផ្តល់អនុគណៈកម្មាធិការនូវៈ

១- សិទ្ធិទទួលពត៌មានដោយគ្មានការរឹតត្បិត អំពីចំនួនជនដែលត្រូវបានដកហូតសេរីភាព នៅក្នុងមន្ទីរឃុំឃាំង ដូចមានចែងក្នុងមាត្រា ៤ ព្រមទាំងចំនួនទីកន្លែង និងទីតាំងនៃកន្លែងទាំងនោះផង ។

២- សិទ្ធិទទួលពត៌មានទាំងអស់ ដែលនិយាយពីប្រព្រឹត្តិកម្មលើជនទាំងនេះ ព្រមទាំងស្ថានភាពនៃការឃុំឃាំងផងដែរ ។

៣- សិទ្ធិចេញចូលគ្រប់កន្លែងឃុំឃាំង ទីតាំង និងរចនាសម្ព័ន្ធនៃមន្ទីរឃុំឃាំង ។

៤- ឱកាសធ្វើសំភាសន៍ដាច់ដោយឡែកជាឯកជនជាមួយជន ដែលត្រូវបានដកហូតសេរីភាព ដោយគ្មានសាក្សី តាមការសំភាសន៍ផ្ទាល់ ឬតាមរយៈអ្នកបកប្រែភាសា បើយល់ថាសមស្រប និងសំភាសន៍ជាមួយបុគ្គលដទៃទៀត ដែលអនុគណៈកម្មាធិការទប់ស្កាត់ យល់ថាអាចផ្តល់ពត៌មានដែលពាក់ព័ន្ធ ។

៥- សេរីភាពជ្រើសរើសទីកន្លែងដែលខ្លួនចង់ធ្វើទស្សនកិច្ច និងបុគ្គលដែលខ្លួនចង់សំភាសន៍ ។

៦- សិទ្ធិធ្វើទំនាក់ទំនងជាមួយអនុគណៈកម្មាធិការទប់ស្កាត់ បញ្ជូនពត៌មានអោយអនុគណៈកម្មាធិការ និង ជួបជាមួយអនុគណៈកម្មាធិការនេះ ។

**មាត្រា ២១.-**

១. គ្មានអាជ្ញាធរ ឬមន្ត្រីណាអាចបញ្ជា អនុវត្ត អនុញ្ញាត ឬមិនអើពើចំពោះ ការដាក់ទណ្ឌកម្មប្រឆាំងនឹងបុគ្គល ឬអង្គការណាមួយពីមូលហេតុដែលបុគ្គលនេះបានផ្តល់ពត៌មានជូនអនុគណៈកម្មាធិការទប់ស្កាត់ ឬប្រតិភូនៃអនុគណៈកម្មាធិការនេះបានទេ ទោះបីជាពត៌មាននោះពិត ឬមិនពិតក្តី ហើយបុគ្គល

ឬអង្គការនេះមិនត្រូវទទួលរងការចោទប្រកាន់តាមវិធីណាមួយបានឡើយ ។

២. ពត៌មានសម្ងាត់ដែលប្រមូលដោយយន្តការទប់ស្កាត់ថ្នាក់ជាតិត្រូវបានរក្សាសិទ្ធិ ។ ពត៌មានផ្ទាល់ខ្លួនមិនអាចត្រូវចុះផ្សាយដោយគ្មានការយល់ព្រមពីសាមីជនបានឡើយ ។

**មាត្រា ២២.-**

អាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋភាគីពាក់ព័ន្ធត្រូវពិនិត្យអនុសាសន៍យន្តការទប់ស្កាត់ និងចូលរួមក្នុងការពិភាក្សាអំពីវិធានការអនុវត្តដែលអាចធ្វើទៅបាន ។

**មាត្រា ២៣.-**

រដ្ឋភាគីនៃពិធីសារបន្ថែមនេះ ជាអ្នកចាត់ចែងការបោះពុម្ពផ្សាយ និងផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំរបស់យន្តការទប់ស្កាត់ថ្នាក់ជាតិ ។

## ជំពូកទី ៥
## សេចក្តីប្រកាស

**មាត្រា ២៤.-**

១. នៅពេលធ្វើសច្ចាប័ន រដ្ឋភាគីទាំងឡាយអាចធ្វើសេចក្តីប្រកាសព្យួរការអនុវត្តន៍កាតព្វកិច្ចរបស់ខ្លួនតាម ជំពូកទី ៣ ឬជំពូកទី ៥ នៃពិធីសារបន្ថែមនេះ ។

២. ការព្យួរនេះត្រូវមានសុពលភាពក្នុងរយៈពេលអតិបរមា ០៣ឆ្នាំ ។ បន្ទាប់ពីមានការអះអាងរបស់រដ្ឋភាគីនិងបន្ទាប់ពីការពិគ្រោះយោបល់ជាមួយអនុគណៈកម្មាធិការទប់ស្កាត់ថ្នាក់ជាតិ គណៈកម្មាធិការប្រឆាំងនឹងអំពើ ទារុណកម្ម អាចពន្យាពេលរយៈពេលនេះបាន ០២ ឆ្នាំ បន្ថែមទៀត ។

## ជំពូកទី ៦
## បទប្បញ្ញត្តិហិរញ្ញវត្ថុ

**មាត្រា ២៥.-**

១. រាល់ការចំណាយរបស់អនុគណៈកម្មាធិការទប់ស្កាត់ គឺជាបន្ទុករបស់អង្គការសហប្រជាជាតិ ។

២. អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ត្រូវចាត់តាំងបុគ្គលិកនិងទីតាំងចាំបាច់ដើម្បីអោយអនុ គណៈកម្មាធិការទប់ស្កាត់អាចបំពេញមុខងារតាមពិធីសារនេះប្រកបដោយជោគជ័យ ។

**មាត្រា ២៦.-**

១. មូលនិធិពិសេស នឹងត្រូវបានបង្កើតស្របតាមនីតិវិធីរបស់មហាសន្និបាត ដែលនឹងត្រូវចាត់ចែងស្របតាមវិធាននិងបទប្បញ្ញត្តិហិរញ្ញវត្ថុនៃអង្គការសហប្រជាជាតិ ដើម្បីជួយឧបត្ថម្ភដល់ការអនុវត្ត

អនុសាសន៍ ដែលអនុគណៈកម្មាធិការទប់ស្កាត់ បានបញ្ជាក់ជូនរដ្ឋភាគីបន្ទាប់ពីទស្សនកិច្ច ព្រមទាំងកម្មវិធីអប់រំរបស់ យន្តការទប់ស្កាត់ថ្នាក់ជាតិ។

២. មូលនិធិនេះ អាចនឹងត្រូវផ្តល់ជូនតាមរយៈវិភាគទានស្ម័គ្រចិត្តរបស់អង្គការរដ្ឋាភិបាល អង្គការអន្តររដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងអង្គភាពឯកជន ឬអង្គភាពសាធារណៈផ្សេងទៀត។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**មាត្រា ២៧.-**

១. ពិធីសារបន្ថែមនេះបើកចំហសំរាប់ចុះហត្ថលេខាដោយរដ្ឋដែលបានចុះហត្ថលេខាដោយអនុសញ្ញានេះ។

២. ពិធីសារបន្ថែមនេះត្រូវមានសច្ចាប័នគ្រប់ចំនួនពីរដ្ឋដែលបានធ្វើសច្ចាប័ន ឬចូលជាសមាជិកអនុសញ្ញា។ រដ្ឋភាគីត្រូវតម្កល់លិខិតុបករណ៍ធ្វើសច្ចាប័ននៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ។

៣. ពិធីសារបន្ថែមនេះបើកចំហសំរាប់ការសុំចូលជាសមាជិក ដោយរដ្ឋដែលបានធ្វើសច្ចាប័ន ឬចូលជាសមាជិក នៃអនុសញ្ញា។

៤. លិខិតសុំចូលជាសមាជិកមានប្រសិទ្ធភាព ដោយការតម្កល់លិខិតុបករណ៍សុំចូលជាសមាជិក នៅអគ្គលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ។

៥. អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ត្រូវជូនពត៌មានដល់រដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើពិធីសារនេះ ឬបានសុំចូលជាសមាជិកអំពីការតម្កល់លិខិតុបករណ៍នៃការធ្វើសច្ចាប័ន ឬសុំចូលជាសមាជិក។

**មាត្រា ២៨.-**

១. ពិធីសារបន្ថែមនេះត្រូវចូលជាធរមានក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការតម្កល់លិខិតុបករណ៍ ឬ លិខិតសុំចូលជាសមាជិកទី ២០ នៅអគ្គលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ។

២. ចំពោះរដ្ឋនិមួយៗដែលធ្វើសច្ចាប័ន ឬសុំចូលជាសមាជិកនៃពិធីសារបន្ថែមនេះ បន្ទាប់ពីការតម្កល់លិខិតុបករណ៍ ឬ លិខិតសុំចូលជាសមាជិកទី២០នៅអគ្គលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ ពិធីសារបន្ថែមនេះត្រូវចូលជាធរមានចំពោះរដ្ឋនេះក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការតម្កល់លិខិតុបករណ៍ ឬ លិខិតសុំចូលជាសមាជិករបស់ខ្លួន។

**មាត្រា ២៩.-**

ពិធីសារបន្ថែមនេះត្រូវមានវិសាលភាពលើគ្រប់រដ្ឋសមាជិកនៃរដ្ឋសហព័ន្ធដោយគ្មានការកំរិត ឬការលើកលែងអ្វីឡើយ។

**មាត្រា ៣០.-**

ក្នុងការធ្វើសច្ចាប័ន ឬសុំចូលជាសមាជិកនៃពិធីសារបន្ថែមនេះ គ្មានរដ្ឋណាមួយអាចរក្សាសិទ្ធិ លើបទប្បញ្ញត្តិណាមួយបានឡើយ ។

**មាត្រា ៣១.-**

បទប្បញ្ញត្តិនៃពិធីសារបន្ថែមនេះ មិនមានអានុភាពប៉ះពាល់ដល់កាតព្វកិច្ចរបស់រដ្ឋភាគី តាមអនុសញ្ញាប្រចាំតំបន់ ដែលបង្កើតប្រព័ន្ធទស្សនកិច្ចតាមមន្ទីរឃុំឃាំងឡើយ ។ អនុគណៈកម្មាធិការទប់ស្កាត់អំពើទារុណកម្ម និងស្ថាប័នទាំងឡាយ ដែលបង្កើតឡើងតាមអនុសញ្ញាប្រចាំតំបន់ទាំងនោះ ត្រូវបានលើកទឹកចិត្តអោយ ពិគ្រោះយោបល់ឬសហការក្នុងគោលបំណងជៀសវាងការត្រួតគ្នា និងដើម្បីលើកកំពស់គោលបំណងនៃពិធីសារនេះអោយមានប្រសិទ្ធភាព ។

**មាត្រា ៣២.-**

បទប្បញ្ញត្តិនៃពិធីសារបន្ថែមនេះ មិនមានអានុភាពប៉ះពាល់ដល់កាតព្វកិច្ចរបស់រដ្ឋភាគីតាមអនុសញ្ញាក្រុងហ្សឺណែវទាំង ៤ ដែលចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ និងពិធីសារបន្ថែមលើអនុសញ្ញាទាំងនោះ ដែលចុះថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ១៩៩៧ ឬឱកាសដែលមានចំពោះរដ្ឋភាគីក្នុងការអនុញ្ញាតអោយគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ក្នុងការធ្វើទស្សនកិច្ចមន្ទីរឃុំឃាំងក្នុងស្ថានភាពដែលមិនស្ថិតក្រោមច្បាប់មនុស្សធម៌អន្តរជាតិ ។

**មាត្រា ៣៣.-**

១. រដ្ឋភាគីអាចប្រកាសបដិសេធពិធីសារបន្ថែមនេះ បានគ្រប់ពេលវេលា តាមរយៈការជូនដំណឹងជាយលក្ខណ៍អក្សរទៅអគ្គលេខាធិការអង្គការសហប្រជាជាតិដែលជាអ្នកត្រូវជូនដំណឹងបន្តទៅរដ្ឋភាគីដទៃទៀតនៃពិធីសារនេះនិងអនុសញ្ញាប្រឆាំងអំពើទារុណកម្ម ។ សេចក្តីប្រកាសបដិសេធត្រូវចូលជាធរមានក្នុង រយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការបានទទួលលិខិតជូនដំណឹង ។

២. សេចក្តីប្រកាសបដិសេធនេះគ្មានអានុភាពរំដោះកាតព្វកិច្ចរបស់រដ្ឋភាគីសាមី តាមពិធីសារបន្ថែមនេះ ដែលពាក់ព័ន្ធនឹងអំពើ ឬស្ថានភាពណាមួយដែលកើតឡើងមុនកាលបរិច្ឆេទ ដែលសេចក្តីប្រកាសបដិសេធចូល ជាធរមានឡើយ ឬសកម្មភាពទាំងឡាយដែលអនុគណៈកម្មាធិការទប់ស្កាត់បានសំរេច ឬអាចសំរេចអនុម័តទៅលើរដ្ឋភាគីសាមីឡើយ ហើយសេចក្តីប្រកាសបដិសេធនេះក៏គ្មានអានុភាពរារាំងការពិចារណារាល់បញ្ហាដែលកំពុងបន្ត ហើយដែលអនុគណៈកម្មាធិការទប់ស្កាត់បាន ពិចារណារួចស្រេចមុនកាលបរិច្ឆេទ ដែលសេចក្តីប្រកាសបដិសេធចូលជាធរមានឡើយ ។

៣. បន្ទាប់ពីកាលបរិច្ឆេទដែលសេចក្តីប្រកាសបដិសេធរបស់រដ្ឋភាគីចូលជាធរមាន អនុគណៈកម្មាធិការទប់ស្កាត់ មិនត្រូវចាប់ផ្តើមពិចារណាបញ្ហាថ្មីណាមួយពាក់ព័ន្ធនឹងរដ្ឋនោះឡើយ ។

**មាត្រា ៣៤.-**

១. រដ្ឋភាគីនៃពិធីសារបន្ថែមនេះអាចលើកសំណើវិសោធនកម្ម ហើយដាក់ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អគ្គលេខាធិការត្រូវជូនដំណឹងពីសំណើនេះទៅរដ្ឋភាគីទាំងអស់នៃពិធីសារបន្ថែមនេះ ដោយមានសំណើសុំអោយរដ្ឋភាគីទាំងនោះជូនដំណឹងមកអគ្គលេខាធិការវិញអំពីចេតនារបស់រដ្ឋទាំងនោះ ថាតើគេចង់ ឬមិនចង់ចូលរួមសន្និបាតរដ្ឋភាគីដើម្បីពិចារណា និងបោះឆ្នោតលើសំណើសុំវិសោធនកម្ម ។ ក្នុងរយៈពេល ៤ខែ បន្ទាប់ពីការជូនដំណឹងនេះ យ៉ាងហោចណាស់មានរដ្ឋភាគីមួយភាគបី (១/៣) ចង់ចូលរួមក្នុងសន្និបាត អគ្គលេខាធិការត្រូវកោះប្រជុំសន្និបាត ក្រោមអធិបតីភាពនៃអង្គការសហប្រជាជាតិ ។ រាល់វិសោធនកម្មដែលអនុម័តដោយសម្លេងភាគច្រើនពីរភាគបី (២/៣) នៃរដ្ឋភាគីដែលវត្តមាននិងបានបោះឆ្នោតក្នុងសន្និបាតនឹងត្រូវដាក់ជូនអោយរដ្ឋភាគីទាំងអស់ដើម្បីឯកភាពយល់ព្រមដោយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

២. វិសោធនកម្មដែលអនុម័តតាមកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវចូលជាធរមាននៅពេលដែលមានការយល់ព្រមពីសម្លេងភាគច្រើនពីរភាគបី (២/៣) នៃរដ្ឋភាគីក្នុងពិធីសារនេះដោយអនុលោមតាមនីតិវិធីរដ្ឋធម្មនុញ្ញរបស់រដ្ឋសាមីនោះ ។

៣. នៅពេលដែលវិសោធនកម្មនេះចូលជាធរមាន វិសោធនកម្មទាំងនោះនឹងមានអានុភាពភ្ជាប់កាតព្វកិច្ចចំពោះរដ្ឋភាគីទាំងអស់ដែលបានឯកភាពយល់ព្រមវិសោធនកម្មនោះ រីឯរដ្ឋដទៃទៀតនៅមានកាតព្វកិច្ច តាមបទប្បញ្ញត្តិនៃពិធីសារនេះ និងវិសោធនកម្មពីមុនដែលគេបានឯកភាពយល់ព្រម ។

**មាត្រា ៣៥.-**

សមាជិកនៃអនុគណៈកម្មាធិការទប់ស្កាត់ និងសមាជិកនៃយន្តការទប់ស្កាត់ថ្នាក់ជាតិ ត្រូវទទួលបាននូវបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិទាំងឡាយដែលចាំបាច់សំរាប់ការបំពេញមុខងាររបស់ខ្លួន ។ សមាជិកនៃអនុគណៈកម្មាធិការទប់ស្កាត់ ត្រូវទទួលបាននូវបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិទាំងឡាយដែលចែងក្នុងផ្នែកទី ២២ នៃអនុសញ្ញា ស្តីពីបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិរបស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ១៩៤៦ ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃផ្នែកទី ២៣ នៃអនុសញ្ញានោះ ។

**មាត្រា ៣៦.-**

ក្នុងពេលធ្វើទស្សនកិច្ចរដ្ឋភាគី ដោយមិនគិតត្រឹមតែបទប្បញ្ញត្តិនិងគោលបំណងនៃពិធីសារនេះ និងបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិឯទៀតដែលខ្លួនអាចទទួលបាន សមាជិកនៃអនុគណៈកម្មាធិការទប់ស្កាត់ត្រូវ:

ក- គោរពច្បាប់និងបទប្បញ្ញត្តិរបស់រដ្ឋដែលខ្លួនធ្វើទស្សនកិច្ច និង

ខ- មិនប្រព្រឹត្តិអំពើ ឬសកម្មភាពណាមួយដែលផ្ទុយពីគោលការណ៍អព្យាក្រិត និងគោលការណ៍អន្តរជាតិ ក្នុងការបំពេញភារកិច្ចរបស់ខ្លួនឡើយ ។

**មាត្រា ៣៧.-**

១. ពិធីសារបន្ថែមនេះដែលធ្វើឡើងជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងភាសាអេស្ប៉ាញ ដែលបានតម្កល់នៅអគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិ ត្រូវមានតម្លៃគតិយុត្តិស្មើគ្នា ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនច្បាប់ចម្លងនៃពិធីសារនេះដោយមានការបញ្ជាក់ជូនរដ្ឋភាគីទាំងអស់ ។